សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធពោលថា អ្វីទាំងអស់ ទាំងមានវិញ្ញាណទាំងគ្មានវិញ្ញាណ កើតពី«សង្ខារ»ការរួមផ្សំ ។

www.hoksavann.org

ថ្ងៃទី១២ មករា ២០១២



«សង្ខារ» ជាពាក្យខ្មែរ ចេញពីភាសាបាលីថា សង្ខារោ មកពី សំ បុព្វបទ កធាតុ ប្រែថា ការតាក់តែង, ការរួមផ្សំ, ការកសាង, ការធ្វើឲ្យកើតជាអ្វីមួយ ដែលបា រាំងថា Corps composé អង់គ្លេសថា Component ។សង្ខារនេះជាតួសភាវធម៌គ្មានរូបរាងសណ្ឋានទ្រង់ទ្រាយអ្វីឡើយ គឺជាឈ្មោះនៃសភាវៈ ដែលផ្សំគ្នាឲ្យកើតជាអ្វីមួយ ហៅថាសង្ខារ ។ ពុទ្ធសាសនាពោលថា អ្វីទាំងអស់ ទាំងមានវិញ្ញាណទាំងគ្មានវិញ្ញាណ ពុំមានតួខ្លួនវាពីកំណើតទេ ដែលបាលីថា «អនត្តា» កើតមានជាអ្វីមួយមកពីការផ្សំ គឺសង្ខារនេះឯង ។ យ៉ាងណាមិញ រូបរាងកាយរបស់មនុស្សសត្វដែលសំគាល់ថាជាខ្លួននោះ គ្មានអ្វីក្រៅពីការផ្សំគឺខន្ធ៥ បានដល់រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ រូបផ្សំមកពីធាតុ៤ គឺធាតុទឹកដីភ្លើងខ្យល់ ចំណែកនាមទាំង៤ គឺវេទនា សញ្ញា សង្ខារ និងវិញ្ញាណ ជាចិត្តនិងចេតសិក កើតពីអាយតនៈខាងក្នុង៦ និងខាងក្រៅ៦ប៉ះទង្គិចគ្នា ដែលហៅថា ផស្សាយតនៈ ទើបកើត ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិ-ញ្ញាណ និងមនោវិញ្ញាណ ។ ការកើតបានជារូបរាងកាយរបស់មនុស្សសត្វ ក៏កើតឡើងពីការផ្សំ ធាតុរបស់មាតាបិតា និងវិបាកវិញ្ញាណរបស់មនុស្សសត្វមកចាប់បដិសន្ធិផង ។

អង្គធាតុទាំងអស់របស់មនុស្សសត្វមានចលនាទៅតាមសក្តានុភាពរបស់វា ដូចជាបេះដូងដើរ សួតដកដង្ហើមចេញចូល ក្រពះរំលាយអាហារជាដើម ឲ្យតែនៅល្អមិនខូចវាតែងមានចលនាជានិច្ច តែបើវាខូចហើយ ទោះបីមានវត្ថុស័ក្តិសិទ្ធិណាបញ្ជាឲ្យដើរក៏វាពុំដើរឡើយ នេះហៅថាសង្ខារ វាមានចលនាជាស្វ័យប្រវត្តិដោយខ្លួនវា ។ សង្ខារតាក់តែងឲ្យមនុស្សសត្វកើតក្នុងសុគតិភពបានសុខចំរើនដោយអំណាចកុសលកម្ម ចំណែកសង្ខារតាក់តែងឲ្យមនុស្សសត្វកើតក្នុងទុគ្គតិភព បានទុក្ខលំបាកដោយអំណាចអកុសលកម្មដែលខ្លួនបានកសាង ពុំមែនដោយវត្ថុស័ក្តិសិទ្ធិណាមួយឡើយ ។

ចំណែកវត្ថុគ្មានវិញ្ញាណ ដូចជាពពួករុក្ខជាតិគ្រប់យ៉ាង ដែលអាចកើតនិងលូតលាស់ឡើងបាន ដោយពូជល្អមិនខូច ហើ-យដុះលើដីមានជីជាតិ មានទឹកមានពន្លឺថ្ងៃ ទើបសង្ខារទាំងនេះកើតឡើងបាន ។ សង្ខារមួយប្រភេទទៀត កើតពីមនុស្សកសាងដូចជាសំណង់គ្រប់យ៉ាងមានផ្ទះជាដើម កើតពីវត្ថុផ្សំ ដូចជាដំបូល ជញ្ជាំង សសរ ផ្ទោងផ្ទាន រនាបរនូតជាដើម មិនមែនផ្ទះពីកំណើតឡើយ ។ នៅក្នុងបដិច្ចសមុប្បទធម៌ ដែលប្រែថា ធម៌កើតឡើងព្រោះអាស្រ័យហេតុនោះ មាននិយាយខាងដើមថា អវិជ្ជាការ មិនដឹងនូវអរិយសច្ច៤មានទុក្ខសច្ចជាដើម នាំឲ្យកើតសង្ខារ ។ សង្ខារក្នុងទីនេះ សំដៅយកចេតនាជាបុណ្យជាបាបរបស់មនុស្សសត្វ ដែលនាំឲ្យកើតវិបាកវិញ្ញាណបន្តបដិសន្ធិចិត្តតទៅទៀត ។ ពោលថា សង្ខារធម៌និងសង្ខតធម៌ មានន័យផ្សេងគ្នា គឺសង្ខារសំដៅយកមនុស្សសត្វឬវត្ថុដែលកំពុងប្រព្រឹត្តទៅ គឺកំពុងផ្សែផ្សំឲ្យកើតជាអ្វីមួយ ដូចជាមនុស្សសត្វដែលកំពុងកើត ផ្ទះដែលកំពុងសង់ជាដើម ។ ចំណែកសង្ខតធម៌ សំដៅយកមនុស្សសត្វ និងវត្ថុមានផ្ទះជាដើម កើតរួចហើយ សង់រួចហើយ ។

សង្ខារទាំងឡាយ ទាំងមានវិញ្ញាណទាំងគ្មានវិញ្ញាណ គ្មានខ្លឹមសារឡើយ កើតឡើងហើយតែងតែវិនាសទៅវិញជាធម្មតា ព្រោះសង្ខារកើតពីគ្រឿងផ្សំ ពុំមានម្ចាស់ ពុំមានតួខ្លួន កើតឡើងជាខាងដើម តាំងនៅជាកណ្តាល និងវិនាសទៅវិញជាទីបំផុត ។ នេះជាច្បាប់ធម្មជាតិរបស់សង្ខារធម៌ កាលណាកើតឡើង តែងវិនាសទៅវិញ ដែលព្រះពុទ្ធបានរកឃើញ ហើយសំដែងប្រាប់មនុស្សសត្វ ។ ដូច្នេះបញ្ជាក់ថា សង្ខារទាំងឡាយដែលមិនមាន ចិត្តវិញ្ញាណ ដូចជាទឹក ភ្លើង ខ្យល់ ផែនដី ព្រះអាទិត្យ ព្រះចន្ទ រុក្ខជាតិជាដើម កើតឡើងឯងតាមច្បាប់ធម្មជាតិ គ្មានព្រះជាម្ចាស់ណាបង្កើតឡើយ ។ ចំណែកសង្ខារដែលមានចិត្តវិញ្ញាណ ដូចជាមនុស្សសត្វ ទេវតា ឥន្ទ ព្រហ្មជាដើម ក៏កើតអំពីកម្មផល របស់មនុស្សសត្វដែលបានកសាង ពុំមានព្រះជាម្ចាស់ណាបង្កើតឡើងឡើយ ។

ក្នុងអរិយសច្ច៤ ទុក្ខសច្ច សេចក្តីទុក្ខបានដល់ការកើតឡើង នៃសង្ខារ គឺខន្ធ៥ជាតួទុក្ខ ត្រូវកំណត់ដឹង ។ សមុទយសច្ច ហេតុដែលនាំឲ្យកើតទុក្ខ បានដល់តណ្ហាត្រូវលះបង់ ។ និរោធសច្ច ការរំលត់ទុក្ខ ត្រូវចំរើនឲ្យកើតឡើង ។ ដូច្នេះតាមកិច្ចក្នុងអរិយសច្ច៤នេះបញ្ជាក់ថា ដើម្បីរំលត់សង្ខារជាតួទុក្ខនេះ ត្រូវរំលត់តណ្ហា ដោយប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ ឈោងយកព្រ និព្វានជាការរំលត់ទុក្ខដោយដាច់ខាត ព្រោះផុតការកើត ចាស់ ឈឺ ស្លាប់ ជាតួអសង្ខតធម៌ ។៚

*　　*

*